# មូលនិធិសង្គ្រោះអាជីវកម្មខ្នាតតូចក្នុងតំបន់ LA : ការណែនាំអំពីការដាក់ពាក្យ

department
of economic
opportunity

COUNTY OF LOS ANGELES

# ទិដ្ឋភាពនៃការដាក់ពាក្យ

**មូលនិធិសង្គ្រោះអាជីវកម្មខ្នាតតូចក្នុងតំបន់ LA ហៅកាត់ (SBRF)** គឺជាកម្មវិធីជំនួយពីនាយកដ្ឋានឱកាសសេដ្ឋកិច្ចតំបន់ LA (Los Angeles) ដែលផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុរហូតទៅដល់ $5,000 ដល់អាជីវកម្មខ្នាតតូចដែលបានជួបប្រទះនិងការបាត់បង់កម្លាំងពលកម្ម ការធ្លាក់ចុះលើចំនួនអតិថិជន ការខូចខាតទ្រព្យសម្បត្តិ ឬការបាត់បង់ប្រាក់ចំណូលចាប់ពីខែមិថុនា ឆ្នាំ 2025 ដែលកើតឡើងដោយលទ្ធផលសកម្មភាពអនុវត្តអន្តោប្រវេសន៍។ ការគាំទ្រនេះមានគោលបំណងក្នុងការជួយដល់អាជីវកម្មអោយបានងើបឡើងវិញពីព្រឹត្តិការណ៍ដែលមិននឹកស្មានដល់ ហើយបានរំខានដល់ប្រតិបត្តិការរបស់ពួកគេ។

ពាក្យស្នើសុំនឹងត្រូវបានបើកទទួលចាប់ពីម៉ោង **9:00 ព្រឹក PST នៅថ្ងៃទី 29 ខែកញ្ញា ឆ្នាំ 2025 រហូតដល់ថ្ងៃទី 31 ខែតុលា ឆ្នាំ 2025 វេលាម៉ោង 5:00 ល្ងាច PST**។ កម្មវិធីនឹងទាមទារអោយលោកអ្នកចំណាយពេលប្រហែល 15 ទៅ 20 នាទីដើម្បីបំពេញពាក្យស្នើសុំ។ ប្រសិនបើចាំបាច់ លោកអ្នកអាចរក្សាទុកនូវវឌ្ឍនភាពនៃពាក្យបំពេញរបស់អស់លោកអ្នក ដែលលោកអ្នកនឹងត្រឡប់មកបំពេញវិញនៅពេលក្រោយ។

## ព័ត៌មានលម្អិតអំពីការផ្តល់មូលនិធិ

**អាជីវកម្មដែលមានសិទ្ធទទួលបានជំនួយរួមមានអាជីវកម្មឥដ្ឋនិងបាយអដែលមានហាងលក់ អ្នកម៉ៅការឯករាជ្យ អ្នកលក់ចល័ត និងអាជីវកម្មតាមផ្ទះដែលមានសិទ្ធិទទួលបានដែលស្របតាមលក្ខណដូចខាងក្រោម៖**

- ដែលបានរងឥទ្ធិពលអវិជ្ជមានតាមរយៈសកម្មភាពអនុវត្តច្បាប់អន្តោប្រវេសន៏
- ដែលមានទីស្នាក់ការកណ្តាលនៅក្នុងរដ្ឋ កាលីហ្វញ៉ា និងប្រតិបត្តិការនៅតំបន់ LA មុន ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ២០២៥ 2025
- ដែលមានប្រាក់ចំនូលមិនទាន់ប្រកាស់ពន្ធចាប់ពី 6 លានដុល្លារ ឬ តិចជាង
- ពាណិជ្ជកម្មត្រូវតែមានបុគ្គលិកចាប់ពី ១០០ នាក់ ឬតិចជាង
- បេក្ខជនស្នើសុំប្រាក់ជំនួយត្រូវតែជាម្ចាស់ពាណិជ្ជកម្មផ្ទាល់
- ម្ចាស់ពាណិជ្ជកម្មត្រូវតែមានប្រភពចំណូលនៅក្នុងការបង់ពន្ធក្នុងឆ្នាំ២០២៤
- ពាណិជ្ជកម្មត្រូវតែមានដំណលការសកម្មនិងការប្រតិបត្តិការដោយមានទំនាក់ទំនងល្អជាមួយប្រជាជនក្នុងតំបន់ ក្នុងរដ្ឋ និងការពន្ធរដ្ឋ និង សិទ្ធដោយអាជ្ញាធរស្របច្បាប់

## ទីតាំងកន្លែងដាក់ពាក្យស្នើសុំ

លោកអ្នកអាចដាក់ពាក្យបានតាមអនឡាញនៅលើគេហទំព័រ៖
**https://lacsmallbizresiliency.aidkit.org/ap ply**

💡 **ត្រូវការជំនួយ?** ប្រសិនបើលោកអ្នកមានបញ្ហាបច្ចេកទេសក្នុងការដាក់ស្នើពាក្យ ឬមានចម្ងល់ផ្សេងៗ លោកអ្នកអាចធ្វើការទំនាក់ទំនងមកកាន់ភ្នាក់ងារផ្តល់ពត៌មាន AidKit ៖

📞 ទូរសព្ទមកកាន់៖ (213) 770-6148 ឬទាក់ទងមកកាន់
📧 អ៊ីម៉ែល៖ support@lacsmallbizresiliency.aidkit.org

លោកអ្នកក៏អាចធ្វើការទាក់ទងមកកាន់ការិយាល័យអាជីវកម្មខ្នាតតូចសម្រាប់ចម្ងល់ទូទៅផ្សេងៗតាមរយៈ៖

📞 ទូរសព្ទមកកាន់៖ (844)-432-4900 (8:30am to 4:00pm) ឬទាក់ទងមកកាន់
📧 អ៊ីម៉ែល៖ osb@opportunity.lacounty.gov.

## ព័ត៌មានលម្អិតអំពីការផ្តល់មូលនិធិ

ពាក្យស្នើសុំដែលដែលស្របតាមលក្ខណនឹងត្រូវបានពិនិត្យនិងធ្វើការវង្វាយតម្លៃរកពិន្ទុដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ដោយភ្នាក់ងារក្នុងតំបន់ LA។ ប្រសិនបើការដាក់ពាក្យមានចំនួនលើសពីមូលនិធិដែលបានផ្តល់ជូន យើងនឹងប្រើប្រាស់ប្រព័ន្ធចាប់ឆ្នោត ។

អាជីវកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចនិងទទួលបានការផ្តល់ប្រាក់ជំនួយសង្គ្រោះរហូតដល់ទៅ **5.000** ដុល្លារ ប្រសិនបើអាជីវកម្មនោះមានប្រតិបត្តិការលើអាជីវកម្មឡឥដ្ឋ និងបាយអ ឬ ទឹកប្រាក់ **2 .500** ដុល្លារ ប្រសិនបើអាជីវកម្មនោះកំពុងមានប្រតិបត្តិការក្នុងនាមជាអ្នកម៉ៅការឯករាជ្យ អ្នកផ្គត់ផ្គង់អ្នកលក់តាមដងផ្លូវ ឬអាជីវកម្មតាមផ្ទះដែលមានលក្ខណៈគ្រប់គ្រាន់។

ការជូនដំណឹងអំពីលទ្ធផលប្រាក់ជំនួយត្រូវបានរំពឹងនឹងប្រកាស់នៅចុងខែវិច្ឆិកា / ធ្នូ ២០២៥ ក្រោយនៃដំណើរការត្រួតពិនិត្យពាក្យស្នើសុំនិងជ្រើសរើស។

## ឯកសារដែលត្រូវការដើម្បីបញ្ចប់នៅក្នុងការបំពេញពាក្យស្នើសុំ៖

ពាក្យស្នើសុំទាមទារអោយមានឯកសារចាំបាច់មួយចំនួន។ នៅក្នុងឯកសារទាំងអស់ សូមប្រាកដថាឈ្មោះអាជីវកម្មនិងព័តមានសំខាន់ៗរបស់លោកអ្នក អាចត្រូវបានមើលឃើញច្បាស់ល្អ។ ប្រសិនបើលោកអ្នកមិនមានឯកសារនោះ នោះពាក្យស្នើសុំនឹងបញ្ឈប់ហើយលោកអ្នកមិនអាចបំពេញ ពាក្យស្នើសុំនេះបានទៀតទេ។ លោកអ្នកអាចធ្វើការទាក់ទងទៅកាន់អង្គភាពសមាគមន៏ពាណិជ្ជកម្មដែលទទួលបានសិទ្ធិពីរដ្ឋាភិបាល (CBO) ដើម្បីជួយលោកអ្នកទទួលបានបានឯកសារដែលទាមទារសម្រាក់ការដាក់ពាក្យ។

លោកអ្នកអាចទាក់ទងមកកាន់ការិយាល័យអាជីវកម្មតូចសម្រាប់សំណួរទូទៅ ប៉ុន្តែកម្មវិធីពាក្យស្នើសុំនឹងមិនអាចឲ្យលោកអ្នកបន្តទៅបំពេញពត៌មាននៅដំណាក់កាលបន្ទាប់នោះទេ លើកលែងតែលោកអ្នកបានបង្ហោះរាល់ឯកសារតម្រូវការចាំបាច់នៅចំណុចនីមួយៗ។

សូមមើលនៅក្នុងបញ្ជីពេញនៃឯកសារដែលទាមទារចាំបាច់នៅទីនេះ។

# អាជីវកម្មដែលមិនបានគោរពតាមលក្ខណ

- អង្គការមិនរកប្រាក់ចំណូល (រួមមានទាំងក្រុមជំនុំឬអង្គការសាសនាផ្សេងទៀត)
- ម្ចាស់ដី (កាលវិភាគប្រាក់ចំណូលអកម្មតាមប្រព័ន្ធអេឡិចត្រូនិច)
- អាជីវកម្មឬក្រុមហ៊ុនដែលកាន់កាប់ដោយមានទំនុកចិត្ត
- អាជីវកម្មឡឥដ្ឋនិងបាយអដែលប្រើប្រាស់ ប្រអប់ P.O. ដែលជាអាស័យដ្ឋានរបស់ពួកគេ ដោយប្រតិបត្តិការពីប្រព័ន្ធផ្ទុកទិន្នន័យដែលបានចែករំលែកបណ្តោះអាសន្ន (ឧទា WeWorks) ។
- អាជីវកម្មដែលបានចូលរួមក្នុងសេវាកម្មវិជ្ជាជីវៈរួមមាន និងមិនមានកំណត់ចំពោះច្បាប់ គណនេយ្យ និងអចលនទ្រព្យ។
- អាជីវកម្មលក់គ្រឿងញៀន ឬថ្នាំ Paraphernalia (ដែលរួមមានទាំងហាងលក់គ្រឿងស្រវឹងនិង ហាងលក់បារី) ក្រុមហ៊ុនដែលមានប្រេនឆាយផ្ទាល់ខ្លួន។
- ក្លឹបសង្គមលក្ខណឯកជន
- ហាងឥណទាន Payday, ហាងបញ្ចាំ និងក្រុមអាជីវកម្មផ្សេងទៀតដែលពាក់ព័ន្ធនឹងសកម្មភាពហិរញ្ញវត្ថុ ដូចជាធនាគារ ក្រុមហ៊ុនហិរញ្ញវត្ថុ និងក្រុមហ៊ុនណាផ្សេងទៀតដែលមានភាគហ៊ុនជាសាច់ប្រាក់
- ក្រុមហ៊ុនដែលចូលរួមក្នុងសកម្មភាពប្រតិបត្តិការហិរញ្ញវត្ថុដែលមានហានិភ័យខ្ពស់ (ឧ. ការលេងតាម Trade អ្នកសម្របសម្រួលលើការទិញលក់ទីផ្សារភាគហ៊ុន)
- ក្រុមហ៊ុនធានារ៉ាប់រង ដូចជា ធានារ៉ាប់រងជីវិត ធានារ៉ាប់រងរថយន្ត ធានារ៉ាប់រងលើផ្ទះ ប័ណ្ណបំណុល និងធានារ៉ាប់រងផ្សេងទៀតដែលស្រដៀងគ្នា។
- ហោរាសាស្រ្ត ទាយតាមការអានបាតដៃ និង tarot ជាដើម។
- ក្លឹបរាត្រី ហាងលក់សៀវភៅសម្រាប់មនុស្សពេញវ័យ និងអាជីវកម្មណាមួយដែលបង្ហាញការផ្សាយបន្តផ្ទាល់ ឬការសម្តែងដែលទំនោរផ្នែកផ្លូវភេទ។
- អាជីវកម្មល្បែងស៊ីសង (ឧទា ឧបករណ៏តាមដានលើការភ្នាល់ កាស៊ីណូ ហ្គេមបឹងហ្គោ)
- Trailer- yards សម្រាប់ផ្ទុកទុក និង junkyards
- ហាងលក់កាំភ្លើងឬគ្រាប់រំសេវ
- ការចែកចាយបោះដុំ និងទីផ្សារពហុកម្រិត
- ក្រុមហ៊ុនដែលមានចំណែកភាគលាភ ឬអាជីវកម្មដែលមានចំណែក 50% ឬច្រើនជាងនេះរាល់ការចំណាយពេលវេលា ឬធនធានរបស់ពួកគេក្នុងសកម្មភាពអាជីវកម្ម
- ការិយាល័យរដ្ឋាភិបាល ឬទីភ្នាក់ងារ
- អាជីវកម្មផ្សេងទៀតដែលអាចត្រូវបានចាត់ទុកថាមិនមានសិទ្ធិដែលបានកំណត់ដោយ DEO ដោយផ្អែកលើព័ត៌មានដែលបានដាក់ជូនដោយអ្នកដាក់ពាក្យស្នើសុំ

# បំពេញពាក្យស្នើសុំរបស់លោកអ្នក

department
of economic
opportunity

COUNTY OF LOS ANGELES

# របៀបចាប់ផ្តើមពាក្យស្នើសុំ

- សូមចូលទៅកាន់គេហទំព័រដាក់ពាក្យស្នើសុំ https://lacsmallbizresiliency.aidkit.org/apply
- សូមបំពេញពាក្យស្នើសុំទៅតាមដំណាក់កាលនីមួយៗដោយធ្វើតាមការណែនាំដាក់ពាក្យស្នើសុំថ្មី



# ជំហានទី១៖ ស្វាគមន៍

ជ្រើសយកភាសាដែលអ្នកពេញចិត្ត (ភាសាអង់គ្លេសឬភាសាអេស្ប៉ាញ) ដើម្បីបំពេញពាក្យស្នើសុំ។



# ជំហានទី១៖ ស្វាគមន៍

**ចាប់ផ្ដើមពាក្យស្នើសុំរបស់លោកអ្នក**

នៅពេលដែលលោកអ្នកបានត្រៀមខ្លួនរួចរាល់ដោយជ្រើសជ្រើស "បន្ទាប់" ឬ "ចាប់ផ្ដើមពាក្យស្នើសុំថ្មី" ។

**បន្តបំពេញពាក្យស្នើសុំរបស់លោកអ្នក**

ដើម្បីបន្តបំពេញពាក្យស្នើសុំរបស់លោកអ្នកបានពីការរក្សាទុកចាស់ សូមចុច "បន្តពាក្យស្នើសុំ" ។ បន្ទាប់មកសូមបញ្ចូលលេខទូរស័ព្ទឬអាសយដ្ឋានអ៊ីមែលដែលលោកអ្នកបានប្រើនៅពេលអ្នកចាប់ផ្ដើមពាក្យស្នើសុំរបស់លោកអ្នក។ បន្ទាប់ពីផ្ទៀងផ្ទាត់ព័ត៌មានទំនាក់ទំនងរបស់លោកអ្នកជាមួយលេខកូដ 6 ខ្ទង់រួចរាល់ លោកអ្នកនឹងទទួលបានការបញ្ជាក់ពីការបន្តបំពេញពាក្យស្នើសុំរបស់អ្នកឡើងវិញ។



# ជំហានទី២៖ សំណួរដែលត្រូវបានគេសួរញឹកញាប់

ពិនិត្យឡើងវិញរាល់សំណួរដែលត្រូវបានគេសួរញឹកញាប់ (FAQs) ដើម្បីត្រៀមខ្លួនលោកអ្នកសម្រាប់ដំណើរការនៃការបំពេញពាក្យស្នើសុំ។

លោកអ្នកអាចស្វែងរកសំណួរដែលត្រូវបានគេសួរញឹកញាប់នៅទីនេះ៖ **https://lacsmallbizresiliency.aidkit.org/p/faqs**

មើលឯកសារពេញលេញដែលត្រូវការបញ្ជីនៅទីនេះ



# ជំហានទី៣៖ សិទ្ធអនុញ្ញាត

សូមពិនិត្យឡើងវិញនិងទទួលយកគោលការណ៍ឯកជនភាពទិន្នន័យរបស់កម្មវិធីពាក្យស្នើសុំ

## Consent to Apply

**Data Privacy**

- I authorize AidKit, Southern California Grantmakers, and Los Angeles County's Department of Economic Opportunity to collect and use my personal information for the purpose of verification and fraud prevention, program communications, eligibility determination, payment processing, evaluation of program impact, and improvement of the AidKit platform and future Los Angeles County programming.
- I authorize AidKit, Southern California Grantmakers, and Los Angeles County's Department of Economic Oppo
contact information to reach out with additional i
programs, and services related to the **LA County**
**Resiliency Fund** and other programs offered by t
- Personal information can include identity informa
government ID, image/video), contact details, de
employment data or my financial information.
- This information may be shared with program adr
identity verification services, or payment process
by the rules of applicable program or by law).
- I understand that my data will not be sold to adve
party partners and that my privacy will be maintai
be used to provide the program service describe
application, improve features, and communicate w
to this application and to share information relate
recovery services. I understand that my data will
accordance with this policy and will not be used f
purposes or sold to external advertisers.

**Your Privacy Acknowledgments**

We collect the information you provide to process your application and, if eligible, deliver program benefits. Please see our Privacy Policy for details on what data we collect, how we use it, and your privacy rights.

By moving forward with this application, you confirm:

- **I understand** I may request access to, correction of, or deletion of my information.
- **I understand** if deleting my data would prevent AidKit from delivering services, detecting fraud, or meeting legal requirements, my deletion requests may not be possible. AidKit will only retain what's necessary and will securely delete it once it is no longer required.
- **I understand** AidKit will not sell my personal information under any circumstances.
- **I understand** I may withdraw consent to receive program-related communications at any time by contacting privacy@aidkit.cloud.

*By moving forward with this application, I accept these terms, agree to receive program-related communications and acknowledge that AidKit will use my information to process my application and provide program services, as described in the Privacy Policy.*

○ Yes, I consent.
○ No, I do not consent.

# ជំហានទី៤៖ ពត៌មានទំនាក់ទំនង

សូមផ្តល់ព័ត៌មានទំនាក់ទំនងសំខាន់ៗរបស់លោកអ្នក

- បញ្ចូលឈ្មោះស្របច្បាប់របស់លោកអ្នកដែលដូចទៅនិងឈ្មោះនៅលើអត្តសញ្ញាណប័ណ្ណដែលចេញដោយរដ្ឋាភិបាលរបស់លោកអ្នក
- សម្គាល់៖ លោកអ្នកត្រូវតែជាម្ចាស់អាជីវកម្មដែលមានភាគហ៊ុនច្រើនជាងគេដើម្បីអាចមានសិទ្ធិបំពេញពាក្យស្នើសុំនេះបាន។
- បញ្ចូលកាលបរិច្ឆេទថ្ងៃខែឆ្នាំកំណើតរបស់លោកអ្នក (លោកអ្នកត្រូវតែមានអាយុចាប់ពី 18 ឆ្នាំឡើងទៅដើម្បីអាចធ្វើការដាក់ពាក្យបាន) ។
- ផ្តល់លេខទូរស័ព្ទរបស់លោកអ្នក (ដែលប្រើសម្រាប់ទំនាក់ទំនងនិងការផ្ទៀងផ្ទាត់) ។
- បញ្ចូលអាសយដ្ឋានអ៊ីមែលរបស់លោកអ្នក (លោកអ្នកនឹងទទួលបានការធ្វើបច្ចុប្បន្នភាពនូវកម្មវិធីពាក្យស្នើសុំតាមរយៈអ៊ីម៉ែលដែលបានផ្តល់ជូន) ។



Contact Information

First we need your name, birthday, and contact information.

If you are coming back to finish an application you started before, please type in your birthday and the phone or email you used last time.

What is your full name?

*Enter your full name (first and last) exactly as it appears on your government-issued ID or other official identification document*

*You must be the owner of the business to complete this application.*

Example Example

What is your birthday?

(You must be 18 years or older to apply.)

Month: 1 - January Day: 01 Year: 2000

# ជំហានទី៤៖ ព័ត៌មានទំនាក់ទំនង

លោកអ្នកនឹងត្រូវបានទាមទារឱ្យធ្វើការផ្ទៀងផ្ទាត់ព័ត៌មានទំនាក់ទំនងដែលលោកអ្នកបានកំពុងផ្តល់ជូន។ លេខកូដផ្ទៀងផ្ទាត់នឹងត្រូវបានផ្ញើទៅអ៊ីម៉ែលនិងទូរស័ព្ទរបស់លោកអ្នក។









# ជំហានទី៥៖ អំពីពាណិជ្ជកម្មរបស់អ្នក

នៅក្នុងផ្នែកនេះលោកអ្នកនឹងផ្តល់ព័ត៌មានអំពីអាជីវកម្មរបស់លោកអ្នក។ ប្រសិនបើចម្លើយរបស់លោកអ្នកបង្ហាញថាអាជីវកម្មរបស់អ្នក**មិនបាន** បំពេញតាមតម្រូវការលក្ខណៈនៃសិទ្ធិទទួលបានរបស់កម្មវិធី នោះពាក្យស្នើសុំរបស់លោកអ្នកនឹងបញ្ឈប់ហើយលោកអ្នកនឹងមិនអាចបន្តបំពេញពាក្យបានទៀតនោះទេ។ លោកអ្នកនឹងឆ្លើយសំណួរនៅខាងក្រោម៖

- ផលប៉ះពាល់លើអាជីវកម្មរបស់លោកអ្នកដែលលោកអ្នកបានជួបប្រទះ និងប្រភេទនៃការរំខាន
- កម្មសិទ្ធិអាជីវកម្ម ប្រភេទអាជីវកម្ម និងរចនាសម្ព័ន្ធផ្លូវច្បាប់របស់លោកអ្នក
- អាស័យដ្ឋានអាជីវកម្មរបស់លោកអ្នក និងឈ្មោះអាជីវកម្មស្របច្បាប់ ដូចដែលបានបង្ហាញនៅលើឯកសារពន្ធ ឬសាជីវកម្មលោកអ្នក។
- លេខ EIN និង SOS របស់លោកអ្នក (ប្រសិនបើមានចំពោះប្រភេទអាជីវកម្មរបស់លោកអ្នក)
- សំណួរទាក់ទងអំពីភូមិសាស្ត្រ និងអាជីវកម្មលោកអ្នក
- ការធានារ៉ាប់រងរបស់លោកអ្នក ចំនួននិយោជិត ប្រាក់ចំណូលប្រចាំឆ្នាំ វិស័យឧស្សាហកម្ម សេវាកម្មដែលដាក់ផ្តល់ជូន និងស្ថានភាពគណនី។



# ជំហានទី៥៖ អំពីពាណិជ្ជកម្មរបស់អ្នក

នៅក្នុងផ្នែកនេះ លោកអ្នកតម្រូវឱ្យធ្វើការកំណត់ពីប្រភពនៃទីតាំងដែលលោកអ្នកធ្វើប្រតិបត្តិការអាជីវកម្ម។ នៅពេលក្រោយ កម្មវិធីពាក្យស្នើសុំនឹងតម្រូវឱ្យលោកអ្នកផ្តល់ឯកសារមួយចំនួនដើម្បីធ្វើការផ្ទៀងផ្ទាត់ប្រភេទអាជីវកម្មដែលអ្នកប្រតិបត្តិការ។

លោកអ្នកត្រូវប្រាកដថាលោកអ្នកបានអានរាល់ជម្រើសនីមួយៗដោយយកចិត្តទុកដាក់ និងយល់ថាតើជម្រើសនោះត្រូវបានកំណត់យ៉ាងណាដោយកម្មវិធីមុនពេលដែលលោកអ្នកធ្វើការការជ្រើសរើសវា?

ប្រសិនបើមិនមានជំរើសណាដែលបានផ្តល់ជូនសមស្របនិងអាជីវកម្មលោកអ្នក សូមធ្វើការទាក់ទងទៅកាន់ក្រុមការងារ Aidkit តាមលេខទូរសព្ទ (213) 770-6148 ឬទាក់ទងតាមអ៊ីម៉ែល lacsmallbizresiliency.aidkit.org សម្រាប់ការណែនាំផ្សេងៗ។ លោកអ្នកត្រូវធ្វើការជ្រើសរើសជម្រើសដែលបានផ្តល់ជូនដើម្បីបន្តបំពេញពាក្យសុំរបស់លោកអ្នក។

**Where do you mainly operate your business? (pick one)**

- (◉) I **own or rent a space** *(not my home)* that customers visit regularly. I operate from a **brick and mortar commercial** location.
- ( ) I run my business **from my home**, and customers come to me there. I operate a **home-based business.**
- ( ) I **travel to meet my customers** where they are and don't have a fixed location. I operate as an **independent contractor** or **service provider.**
- ( ) I run a **sidewalk business** where customers come to me (truck, cart, stand, or market). I operate as a **sidewalk vendor.**
- ( ) I run my business **entirely online** and never meet customers in person. I operate an **online-only business.**

A **brick and mortar** commercial business means you own or rent a space outside of your home (you do not live there) where customers regularly visit.

For example, this could be a shop, restaurant, barbershop, salon, gym, studio, or office.

It must be **located in a commercial zone** and have an establishment license or permit to legally operate. Shared spaces such as WeWorks and P.O. Boxes do not qualify.

Please confirm this is your business type, or change your answer above. If none of the options seem to fit, reach out to us at (213) 770-6148 or support@lacsmallbizresiliency.aidkit.org before proceeding and we'll help you get it sorted.

# បង្ហោះឯកសារ

នៅក្នុងដំណាក់ការបន្ទាប់ លោកអ្នកតម្រូវឱ្យធ្វើការបង្ហោះឯកសារដើម្បីបញ្ជាក់ពត៌មានជាមួយការផ្ទៀងផ្ទាត់ប្រតិបត្តិការអាជីវកម្មរបស់លោកអ្នកនិងសិទ្ធិទទួលបានជំនួយ។

លោកអ្នកតម្រូវអោយបង្ហោះឯកសារចាំបាច់ដើម្បីបំពេញពាក្យស្នើសុំ។

ឯកសារទាំងអស់ត្រូវតែមានពត៌មានដូចគ្នាទៅនិងពត៌មានដែលបានផ្តល់ជូនដល់កម្មវិធីពាក្យស្នើសុំរបស់លោកអ្នក។

ប្រសិនបើលោកអ្នកមិនមានឯកសារទាំងនោះទេ កម្មវិធីពាក្យស្នើសុំនឹងត្រូវបានបញ្ឈប់។ លោកអ្នកអាចនឹងត្រឡប់មកបំពេញពាក្យស្នើសុំវិញនៅពេលណាមួយក៏បាន ដរាបណាមុនថ្ងៃផុតកំណត់ **ថ្ងៃទី 31 ខែតុលាឆ្នាំ 2025 នៅម៉ោង 5:00 ល្ងាច PST**។ ប្រសិនបើលោកអ្នកមិនត្រលប់មកបញ្ចូលឯកសារដែលតម្រូវអោយបង្ហោះមុនថ្ងៃផុតកំណត់ពាក្យស្នើសុំរបស់លោកអ្នកនោះទេ លោកអ្នកនឹងមិនទទួលបានសិទ្ធិក្នុងការទទួលបានជំនួយនោះទេ។

បន្ទាប់ពីបានដាក់បញ្ជូនពាក្យស្នើសុំរបស់លោកអ្នក លោកអ្នកមិនអាចត្រឡប់ចូលទៅក្នុងកម្មវិធីរបស់លោកអ្នកដើម្បីធ្វើបច្ចុប្បន្នភាពឬផ្លាស់ប្តូរឯកសារបាននោះទេ។ សូមប្រាកដថាឯកសារទាំងអស់មានពត៌មានត្រឹមត្រូវមុនធ្វើការដាក់ស្នើបញ្ជូន។ ប្រសិនបើលោកអ្នកត្រូវបានជ្រើសរើសសម្រាប់ការពិនិត្យឡើងវិញយើងអាចនឹងទាក់ទងទៅកាន់លោកអ្នកសម្រាប់ពត៌មានបន្ថែមអំពីឯកសាររបស់លោកអ្នក។

ប្រសិនបើលោកអ្នកត្រូវការជំនួយក្នុងការស្វែងយល់បន្ថែមពីសិទ្ធិទទួលបានជំនួយ ឬថាតើឯកសារលោកអ្នកអាចប្រើប្រាស់បានឬអត់ លោកអ្នកអាចធ្វើការហៅទៅកាន់ភ្នាក់ងារ ពាណិជ្ជកម្មខ្នាតតូចតំបន់ LA តាមលេខទូរសព្ទ (844) 432-4900 សម្រាប់ជំនួយបន្ថែម។ ខណៈពេលដែលពួកគេមិនអាចជួយលោកអ្នកក្នុងការបំពេញពាក្យស្នើសុំ ឬសម្រេចលើការប្រមូលឯកសារ តែពួកគេអាចនឹងជួយគាំទ្រយោបល់លោកអ្នកក្នុងការយល់ដឹងថាតើឯកសារដែលអ្នកអាចបានផ្តល់ជូនអាចទទួលយកបានសម្រាប់កម្មវិធីដែរឬយ៉ាងណា។

ចុច<u>ត្រង់នេះ</u>សម្រាប់ស្វែងរកបញ្ជីឯកសារទាមទារសម្រាប់បំពេញពាក្យស្នើសុំ។.

# ជំហានទី 6: ការប្រមូលឯកសារអត្តសញ្ញាណ

នៅក្នុងផ្នែកនេះ លោកអ្នកតម្រូវឱ្យធ្វើការបង្ហោះឯកសារ ដើម្បីធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់លោកអ្នក។

ដើម្បីបញ្ចប់ការផ្ទៀងផ្ទាត់អត្តសញ្ញាណ លោកអ្នកនឹងទទួលបានសារបញ្ជាក់អោយធ្វើការថតរូបផ្ទាល់របស់លោកអ្នក។ លោកអ្នកនឹងទទួលបានតំណភ្ជាប់ធ្វើទៅកាន់លោកអ្នកអាចតាមរយៈសារ ឬអ៊ីម៉ែល ឬបំពេញវានៅលើកុំព្យូទ័រលើតុរបស់លោកអ្នក។

សម្រាប់បញ្ជីឯកសារចាំបាច់ទាំងអស់ សូមចុចនៅទីនេះ។









# ជំហានទី 6: ការប្រមូលឯកសារអត្តសញ្ញាណ

នៅក្នុងផ្នែកនេះ លោកអ្នកតម្រូវឱ្យបង្ហោះឯកសារដើម្បីធ្វើការផ្ទៀងផ្ទាត់ប្រតិបត្តិការអាជីវកម្មរបស់លោកអ្នកនិងសិទ្ធិទទួលបាន។ ប្រសិនបើលោកអ្នកជាអ្នកលក់តាមដងផ្លូវ ឬអាជីវកម្មចល័ត សូមមើលទៅទំព័របន្ទាប់នៅក្នុងមគ្គុទេសក៍នេះសម្រាប់ព័ត៌មានបន្ថែមអំពីការបង្ហោះឯកសារឡើងរបស់លោកអ្នក។

លោកអ្នកនឹងធ្វើការបង្ហោះឯកសារដើម្បីធ្វើការផ្ទៀងផ្ទាត់៖

- ឯកសារជាម្ចាស់អាជីវកម្មនិងប្រភពប្រាក់ចំណូល
- ឯកសារបញ្ជាក់ប្រាក់ចំណូលប្រចាំឆ្នាំ ដែលមាន 6 លានដុល្លារឬតិចជាង
- ឯកសារដែលបញ្ជាក់ថាអាជីវកម្មមានបុគ្គលិកតិចជាង 100 នាក់
- ឯកសារដែលបញ្ជាក់ថាមានទីតាំងអាជីវកម្មក្នុងតំបន់ដែលមានបញ្ហា
- ឯកសារបញ្ជាក់ប្រភេទអាជីវកម្មដែលអ្នកបានប្រតិបត្តិការ
- មានប្រវត្តិពិន្ទុល្អជាមួយការបង់ពន្ធនិងកម្មសិទ្ធិបញ្ញា

សម្រាប់បញ្ជីឯកសារចាំបាច់ទាំងអស់ សូមចុចនៅទីនេះ។


Business Document Collection

**Important Information About Document Uploads.**

**Documents are required to complete this application.**
If you need to pause your application to gather your documents, you can return at any time to upload it. The application will resume where you left off.

For each document requested, you will be asked if you have the document to upload now or if you need help from a staff member in person. If you choose to get support from a staff member, your application will pause while you go in-person to receive help. **Please note**, if you go in-person for assistance, you will **still be required to upload all required documentation** for this application by the application deadline.

Once you submit your application, you will not be able to make changes or upload additional documents.

**TIP:** To ensure that your application is processed in a timely manner, if taking a picture of your documents, please hold your documents upright and within the frame. If your document is blurry, please retake the picture.


**We need to gather documentation to verify that your business was operating prior to June 1, 2025, earned less than $6 million in gross revenue, and that you are the majority owner.**

**To verify this information we need your 2023 or 2024 tax return including your schedule C, showing:**

- Owner's full name
- Business name
- Business address
- Gross receipts or business income (even if $0, indicates business was active or maintained)
- Ownership status (Schedule C)

**Do you have your 2023 or 2024 tax document?**

- Yes, I have my tax document
- No, I do not. I will call the LA County Office of Small Business at (844) 432-4900 for additional support.
- No, I do not. My business has been open less than 1 year and I have not yet filed this tax document

**Upload your document(s) here.**

*NOTE: You may only upload 20 pages at a time. If you need to upload more than 20 pages, you will need to separate them into different documents and upload them separately.*

Upload Document | Take Photo

Select or drag files here to upload

# ជំហានទី ៦៖ ការប្រមូលឯកសារអាជីវកម្ម (អ្នកលក់តាមដងផ្លូវ និងអាជីវកម្មចល័ត)

រាល់អ្នកលក់តាមចិញ្ចើមផ្លូវនិងអាជីវកម្មចល័តទាំងអស់តម្រូវអោយ**ធ្វើការផ្ទៀងផ្ទាត់ដោយផ្ទាល់**ជាមួយដៃគូសហគមន៍ណាមួយរបស់យើង ដើម្បីធ្វើការបញ្ជាក់ព័ត៌មានលម្អិតអំពីអាជីវកម្មរបស់លោកអ្នក ដើម្បីឱ្យយើងអាចដំណើរការពាក្យស្នើសុំរបស់លោកអ្នកបាន។ **បើលោកអ្នកមិនបានធ្វើការផ្ទៀងផ្ទាត់នេះទេ នោះពាក្យស្នើសុំរបស់លោកអ្នកនឹងមិនមានសិទ្ធិទទួលបានជំនួយនោះទេ។**

លោកអ្នកក៏អាចធ្វើការបង្ហោះឯកសារពាក់ព័ន្ធដើម្បីធ្វើការផ្ទៀងផ្ទាត់អាជីវកម្មរបស់លោកអ្នក។ ការផ្ទៀងផ្ទាត់នេះមិនធានាថាលោកអ្នកនឹងត្រូវបានជ្រើសរើសសម្រាប់ការផ្តល់មូលនិធិទេ។ ទោះជាយ៉ាងណាក៏ដោយ វាក៏អាចជួយបង្កើនឱកាសរបស់លោកអ្នកក្នុងការទទួលបានការជ្រើសរើស។ ប្រសិនបើលោកអ្នកមានឯកសារនេះ លោកអ្នកត្រូវបានលើកទឹកចិត្តក្នុងការបង្ហោះឯកសារទាំងនោះ។

**លោកអ្នកអាចធ្វើការបង្ហោះឯកសារពាក់ព័ន្ធបានដោយមិនតម្រូវចាំបាច់៖**

- ឯកសារសិទ្ធិអនុញ្ញាតលក់ដូរកាលីហ្វ័រញ៉ា
- ឯកសារចុះឈ្មោះឈ្មោះអាជីវកម្មប្រឌិត (DBA)
  - ឯកសារត្រូវតែមានសុពលភាព ឬបានបន្តសុពលភាពក្នុងរយៈពេល 12 ខែ ចុងក្រោយ
- លិខិតចុះឈ្មោះអាជីវកម្មលក់ដូរតាមចិញ្ចើមផ្លូវដែលចេញដោយអាជ្ញាធរតំបន់ LA (ឧទា ផ្លូវថ្មើរជើងក្នុងទីក្រុង LA និង លិខិតអនុញ្ញាអាជីវកម្មនៅក្នុងសួនលើផ្លូវ LA)
  - លិខិតត្រូវតែមានសុពលភាពឬបានបន្តសុពលភាពក្នុងរយៈពេល 12 ខែចុងក្រោ
- លិខិតបញ្ជាក់ចេញពីសុខភាពសាធារណៈពីតំបន់ LA (ប្រតិបត្តិការម្ហូបអាហារចល័ត ហៅកាត់ - CMFO)
  - លិខិតត្រូវតែមានសុពលភាពឬបានបន្តសុពលភាពក្នុងរយៈពេល 12 ខែចុងក្រោយ






# ជំហានទី៧៖ សំណួរពីបទពិសោធអ្នកទទួល AidKit

មុនពេលលោកអ្នកធ្វើការពិនិត្យមើលពាក្យស្នើសុំរបស់លោកអ្នកសម្រាប់ការដាក់ស្នើបញ្ជូន លោកអ្នកតម្រូវឱ្យធ្វើការបំពេញការស្ទង់មតិ (មិនតម្រូវចាំបាច់) អំពីបទពិសោធន៍របស់លោកអ្នកក្នុងការបំពេញពាក្យស្នើសុំជាមួយវេទិកា AidKit។

AidKit គឺជាក្រុមហ៊ុនបច្ចេកវិទ្យាដែលគ្រប់គ្រងកម្មវិធីពាក្យស្នើសុំនិងធ្វើចេញការទូទាត់។

ការឆ្លើយតបរបស់លោកអ្នកនឹងជួយឱ្យ AidKit ធានាបាននូវបទពិសោធន៍វិជ្ជមានងាយស្រួល និងជាមួយគុណតម្លៃ សម្រាប់អ្នកប្រើប្រាស់នាពេលខាងមុខ។ លោកអ្នកអាចនឹងចំណាយពេលតិចជាង 3 នាទីដើម្បីឆ្លើយសំណួរទាំងអស់។

សំណួរទាំងនេះគឺតម្រូវជាចាំបាច់ហើយចម្លើយរបស់លោកអ្នកក៏នឹងមិនជះឥទ្ធិពលដល់សិទ្ធិទទួលបានជំនួយរបស់លោកអ្នកសម្រាប់កម្មវិធីពាក្យស្នើសុំនេះនោះទេ។  ប្រសិនបើលោកអ្នកចង់រំលងសំណួរណាមួយ លោកអ្នកគ្រាន់តែជ្រើសរើស "បន្ទាប់" ។



# ជំហានទី 8៖ ការផ្ទៀងផ្ទាត់ CBO

- ពិនិត្យមើលព័ត៌មានទាំងអស់ដែលបានបញ្ចូលដោយប្រាកដថាមានភាពត្រឹមត្រូវ។
- បំពេញពាក្យដោយបញ្ជាក់ពីចំណេះដឹងខ្ពស់បំផុតរបស់លោកអ្នកដែលថារាល់ព័ត៌មានដែលបានបញ្ចូលគឺពិតនិងត្រឹមត្រូវ។
- អាជីវកម្មខ្លះប្រហែលជាអាចតម្រូវអោយទៅជួបផ្ទាល់ជាមួយអង្គការអាជីវកម្មសមាគមន៍ (CBO) ដើម្បីបញ្ចប់ការផ្ទៀងផ្ទាត់ពាក្យស្នើសុំរបស់ពួកគេ។ សូមមើលព័ត៌មានលម្អិតបន្ថែមអំពីដំណើរការនេះនៅទំព័របន្ទាប់។
- ចំណាំ៖ បន្ទាប់ពីបញ្ជូនពាក្យស្នើសុំរបស់លោកអ្នក លោកអ្នកមិនអាចចូលទៅកាន់គណនីដើម្បីធ្វើការផ្លាស់ប្តូរពត៌មានបាននោះទេ។ ត្រូវប្រាកដថារាល់ព័ត៌មានដែលលោកអ្នកបានបញ្ចូលនិងឯកសារដែលបានបង្ហោះគឺពិតជាត្រឹមត្រូវមុនពេលចុចបញ្ជូន។



# ជំហានទី 8៖ ការផ្ទៀងផ្ទាត់ CBO

- បេក្ខជនដែលកំពុងមានប្រតិបត្តិការនៅក្រៅតំបន់អនុវត្តច្បាប់សហព័ន្ធនិងអ្នកលក់តាមចិញ្ចើមថ្នល់ទាំងអស់នឹង**តម្រូវ**ឱ្យបំពេញការផ្ទៀងផ្ទាត់ដោយផ្ទាល់ជាមួយអង្គការសហគមន៍ (CBO)។
- ប្រសិនបើលោកអ្នកតម្រូវឱ្យមានការផ្ទៀងផ្ទាត់ CBO នេះ លោកអ្នកនឹងឃើញការណែនាំនៅផ្នែកត្រួតពិនិត្យឡើងវិញ និងផ្នែកបញ្ជូនពាក្យស្នើសុំ ដែលលម្អិតបន្ថែមពីមូលហេតុដែលទាមទារអោយមានការផ្ទៀងផ្ទាត់សម្រាប់អាជីវកម្មនិងជំណាក់កាលបន្ទាប់ដែលលោកអ្នកត្រូវធ្វើ។
- ការផ្ទៀងផ្ទាត់ **ត្រូវតែបញ្ចប់ដោយបេក្ខជនមុនថ្ងៃនៃការបរិច្ឆេទផុតកំណត់** ថ្ងៃសុក្រ ថ្ងៃទី 31 ម៉ោង 5:00PM PST បើមិនដូច្នេះពាក្យស្នើសុំនឹងមិនទទួលបានសិទ្ធិតាមលក្ខណ។
- ប្រសិនបើលោកអ្នកតម្រូវឱ្យមានការផ្ទៀងផ្ទាត់ CBO នេះ លោកអ្នកនឹងទទួលបានអ៊ីមែលជាមួយពត៌មានលម្អិតនិងបញ្ជីនៃការចូលរួមរបស់ CBO។ លោកអ្នកត្រូវបង្ហាញអ៊ីមែលនេះទៅកាន់ដៃគូ CBO ដើម្បីទទួលបានការគាំទ្រយោបល់។
- ពាក្យស្នើសុំរបស់លោកអ្នកនឹងត្រូវបានបញ្ជូនដោយស្ថិតនៅក្នុងស្ថានភាព (កំពុងរងចាំ) ដរាបទាល់តែជំហាននេះបានបញ្ចប់។



# ជំហានទី 8៖ ពិនិត្យនិងដាក់ស្នើបញ្ជូន

ចុច "បញ្ជូន" នៅពេលលោកអ្នកបានបានពិនិត្យពត៌មានទាំងអស់

បន្ទាប់ពីចុចបញ្ជូន លោកអ្នកនឹងទទួលបានអ៊ីម៉ែលដែលបញ្ជាក់ពីការទទួលបានពាក្យស្នើសុំរបស់លោកអ្នក និងពត៌មានសម្រាប់ជំហានបន្ទាប់ ណាមួយដែលតម្រូវ ចាំបាច់សម្រាប់អាជីវកម្មរបស់លោកអ្នក។

អ៊ីមែលដែលនឹងបញ្ជូនគឺចេញមកពីអ៊ីម៉ែលក្រុមការងារ lacsmallbizresiliency.aidkit.org



## ជំនួយសម្រាប់ការដាក់ពាក្យស្នើសុំនិងជំនួយគាំទ្រផ្សេងៗ

💡 **ត្រូវការជំនួយ?** ប្រសិនបើលោកអ្នកមានបញ្ហាបច្ចេកទេសក្នុងការដាក់ស្នើពាក្យ ឬមានចម្ងល់ផ្សេងៗ លោកអ្នកអាចធ្វើការទំនាក់ទំនងមកកាន់ភ្នាក់ងារផ្តល់ពត៌មាន AidKit ៖

📞 ទូរសព្ទមកកាន់៖ (213) 770-6148 ឬទាក់ទងមកកាន់
✉️ អ៊ីម៉ែល៖ support@lacsmallbizresiliency.aidkit.org

លោកអ្នកក៏អាចធ្វើការទាក់ទងមកកាន់ការិយាល័យអាជីវកម្មខ្នាតតូចសម្រាប់ចម្ងល់ទូទៅផ្សេងៗតាមរយៈ៖

📍 4716 E. Cesar E. Chavez, Los Angeles, CA 90022.
📞 ទូរសព្ទមកកាន់៖ (844)-432-4900 (8:30am to 4:00pm) ឬទាក់ទងមកកាន់
✉️ អ៊ីម៉ែល៖ osb@opportunity.lacounty.gov.

ទូរសព្ទមកកាន់៖ (844)-432-4900 (8:30am to 4:00pm) ឬទាក់ទងមកកាន់

# ការរំលឹកចុងក្រោយ

✅ ការបិទពាក្យស្នើសុំនឹងត្រូវបញ្ចប់ត្រឹមមុនថ្ងៃសុក្រ ថ្ងៃទី 31st ខែតុលា ម៉ោង 5:00PM PST.

លោកអ្នកមិនអាចចាប់ផ្តើមឬធ្វើការបន្តបំពេញពាក្យស្នើសុំបានទៀតនោះទេ

✅ រាល់ពាក្យស្នើសុំដែលបានបញ្ជូនហើយមិនអាចធ្វើការកែប្រែបាននោះទេ

✅ មូលនិធិមានចំនួនកំណត់ និងមិនមានការធានានោះទេ។

✅ សូមធ្វើការរងចាំ—រាល់ការធ្វើបច្ចុប្បន្នភាពផ្សេងៗ នឹងត្រូវបានផ្ញើទៅកាន់ សារ ឬ អ៊ីម៉ែលរបស់លោកអ្នក

**តាមរយៈការអនុវត្តតាមការណែនាខាងលើនេះ លោកអ្នកនឹងយល់ច្រើនតម្រូវការនិងលកខណ្ឌក្នុងដំណើរការនៃការដាក់ពាក្យស្នើសុំ។ ប្រសិនបើលោកអ្នកមានចង្ងល់ផ្សេងៗ សូមស្វែងរកជំនួយពីក្រុមការងារផ្តល់ព័ត៍មាន!**

department of economic opportunity
COUNTY OF LOS ANGELES